# នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles

# បច្ចុប្បន្នភាពសម្រាប់ឪពុកម្តាយ និងអាណាព្យាបាល ដែលមានកូនគ្រប់អាយុចូលរៀន ការទប់ស្កាត់ការរីករាលដាលនៃជំងឺ COVID-19 នៅក្នុងសាលារៀនកម្រិត TK-12

ឯកសារនេះពិនិត្យលើគោលការណ៍បច្ចុប្បន្ន និងជំហានសកម្មភាពសំខាន់ៗដើម្បីរក្សាសុវត្ថិភាពកុមារនៅក្នុងសាលារៀនកម្រិត TK-12 ចំនួន 3040 របស់ខោនធី Los Angeles។ នៅទំព័របញ្ចប់ អ្នកនឹងរកឃើញធនធានដែលអ្នកអាចទទួលបាន រួមទាំងកន្លែងដែលត្រូវទូរស័ព្ទទៅ ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម ឬត្រូវការជំនួយលើការបង្ការ ឬថែទាំសម្រាប់ជំងឺ COVID-19។

## 1. កំណត់អត្តសញ្ញាណកុមារដែលមានឆ្លងមេរោគ។



នៅពេលសាលារៀនបើកដំណើរការឡើងវិញនៅទូទាំងខោនធី Los Angeles សាលារៀនរបស់កូនអ្នកប្រហែលជាតម្រូវឱ្យពួកគេធ្វើតេស្តរកមេរោគ COVID-19 តាមកាលវិភាគទៀងទាត់មួយចំនួន ហើយជាញឹកញាប់គឺមួយសប្តាហ៍ម្តង។ ច្បាប់របស់សុខភាពសាធារណៈមិនតម្រូវឱ្យសាលារៀនធ្វើតេស្តរកមេរោគចំពោះក្មេងៗទេ ប៉ុន្តែតំបន់សាលារៀន (school districts) នៅក្នុងខោនធីជាច្រើនមានគម្រោងធ្វើតេស្តចំពោះសិស្សទាំងអស់ ឬយ៉ាងហោចណាស់សិស្សដែលមិនបានចាក់ថ្នាំបង្ការពេញលេញទាំងអស់ ជារៀងរាល់សប្តាហ៍។ សាលារៀនកំពុងខិតខំប្រឹងប្រែង ពីព្រោះពួកគេទទួលស្គាល់ថា ការធ្វើតេស្តបន្ថែមពីលើការពាក់ម៉ាស់ និងជំហានបង្ការផ្សេងទៀត គឺជាមធ្យោបាយសំខាន់ដើម្បីការពារសុវត្ថិភាពរបស់កុមារ និងបុគ្គលិក។

## ហេតុអ្វីបានជាការធ្វើតេស្តលើក្រុមកុមារទាំងមូលមានសារៈសំខាន់?

- ដោយសារតែមេរោគ COVID-19 ប្រភេទ Delta ដែលជាពូជមេរោគដែលយើងកំពុងមើលឃើញមាននៅពាសពេញខោនធី Los Angeles ឆ្លងរាលដាលបានយ៉ាងងាយស្រួលពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ជាងប្រភេទមេរោគដែលយើងបានជួបប្រទះកាលពីឆ្នាំមុន។
- ពីព្រោះមនុស្សម្នាក់អាចឆ្លងដោយមិនមានរោគសញ្ញានោះទេ។ អ្នកទាំងនោះប្រហែលជាមិនទាន់ដល់ដំណាក់កាលនៃជំងឺដែលអាចមានរោគសញ្ញាបង្ហាញចេញមក។ ឬពួកគេអាចជាមនុស្សម្នាក់ដែលអាចឆ្លងកាត់ការឆ្លងដោយមិនបង្ហាញរោគសញ្ញាទេ ប៉ុន្តែអាចរាលដាលការឆ្លងដល់មនុស្សដទៃទៀតដែលអាចធ្លាក់ខ្លួនឈឺបាន។
- ការធ្វើតេស្តកាន់តែមានសារៈសំខាន់ និងមានប្រយោជន៍នៅពេលដែលមានមេរោគនេះជាច្រើនកំពុងរាតត្បាត និងមានអ្នកផ្ទុកមេរោគជាច្រើននៅក្នុងសហគមន៍ ដូចជានៅពេលបច្ចុប្បន្ននេះ។ នៅពេលដែលវត្តមានរបស់មេរោគកាន់តែទាបទៅនៅក្នុងសហគមន៍ ការធ្វើតេស្តទៅលើក្រុមមនុស្សធំៗដែលមិនមានរោគសញ្ញា ហើយគ្មានកត្តាហានិភ័យពិសេសនៃការឆ្លងមេរោគបាន ក្លាយជាចំណុចមិនសូវមានប្រយោជន៍ឡើយ ហើយអ្នកអាចឃើញសាលារៀនមួយចំនួនធ្វើតេស្តលើសិស្សក្នុងចំនួនតិចតួចនៅពេលដែលកត្តានេះកើតឡើង ឬបញ្ឈប់ទាំងស្រុងតែម្តង។

ការធ្វើតេស្តអនុញ្ញាតឱ្យសាលារៀនកំណត់អត្តសញ្ញាណអ្នកដែលឆ្លងមេរោគ ជូនដំណឹងដល់ឪពុកម្តាយ និងបញ្ជូនពួកគេទៅផ្ទះដើម្បីដាក់ឱ្យនៅដាច់ដោយឡែកពីអ្នកដទៃជាបន្ទាន់ ដើម្បីកាត់បន្ថយហានិភ័យនៃការរីករាលដាលនៅក្នុងសាលារៀន។

- ប្រសិនបើអ្នកត្រូវបានគេជូនដំណឹងថា កូនរបស់អ្នកបានធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ឬថាកូនរបស់អ្នកមានរោគសញ្ញានៃជំងឺ COVID-19 នៅពេលពួកគេនៅសាលារៀន សាលារៀននឹងទាក់ទងទៅអ្នកជាបន្ទាន់។ អ្នកនឹងត្រូវបានស្នើសុំឱ្យទៅទទួលយកកូនរបស់អ្នក។ អ្នកក៏នឹងទទួលបានព័ត៌មានអំពីវិធីថែទាំកូនរបស់អ្នក និងវិធីការពារគ្រួសារ និងមិត្តភក្តិពីការឆ្លងពីកូនអ្នកដែលផ្ទុកមេរោគដែរ។ សូមតាមបន្តតំណភ្ជាប់នៅទំព័របញ្ចប់នៃឯកសារនេះ ប្រសិនបើអ្នកចង់ស្វែងយល់បន្ថែម។
- ខណៈពេលដែលកូនរបស់អ្នកនៅផ្ទះ អ្នកគួរតែទទួលបានការហៅទូរស័ព្ទពីបុគ្គលិកនៃនាយកដ្ឋានសុខភាពសាធារណៈរបស់យើង។ អ្នកដែលហៅទូរស័ព្ទទៅអ្នកនឹងសហការជាមួយអ្នកដើម្បីស្វែងរកកន្លែងដែលកូនរបស់អ្នកបានប៉ះពាល់នឹងមេរោគ ហើយតើមានគ្រួសារមិត្តភក្តិ ឬអ្នកជិតខាងដែលអាចបានប៉ះពាល់នឹងមេរោគពីកូនរបស់អ្នកឬទេ។

នៅពេលដែលអ្នកទទួលបានការហៅទូរស័ព្ទពីបុគ្គលិកសុខភាពសាធារណៈ វានឹងបង្ហាញនៅលើទូរស័ព្ទរបស់អ្នកជាពាក្យ “LA PublicHealth” ឬមានលេខ 1-833-641-0305។ សូមប្រាកដថាឆ្លើយតបនឹងការហៅនេះដើម្បីឱ្យអ្នកអាចទទួលបានព័ត៌មានសំខាន់ៗអំពីការថែរក្សាកូន និងអ្នកដទៃនៅក្នុងគ្រួសាររបស់អ្នក។ បុគ្គលិកសុខភាពសាធារណៈក៏នឹងពន្យល់ថាតើកូនរបស់អ្នកត្រូវការនៅផ្ទះ និងនៅដាច់ដោយឡែកពីអ្នកដទៃរយៈពេលប៉ុន្មាន។

- ប្រសិនបើកូនរបស់អ្នកមានរោគសញ្ញា និងបានលទ្ធផលធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ឬប្រសិនបើគ្រូពេទ្យរបស់ពួកគេគិតថាពួកគេមានជំងឺ COVID-19 ពួកគេត្រូវតែស្នាក់នៅផ្ទះរហូតដល់៖
    - យ៉ាងហោចណាស់ 10 ថ្ងៃ ចាប់តាំងពីពួកគេមានរោគសញ្ញាជាលើកដំបូង និង
    - ពួកគេមិនមានគ្រុនក្តៅយ៉ាងហោចណាស់ 24 ម៉ោង (ដោយមិនប្រើថ្នាំបន្ថយកម្តៅ) និង
    - រោគសញ្ញារបស់ពួកគេបានធូរស្បើយឡើង
- ប្រសិនបើពួកគេបានលទ្ធផលធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ប៉ុន្តែមិនមានរោគសញ្ញាអ្វីទេ៖
    - ពួកគេត្រូវតែនៅផ្ទះរយៈពេល 10 ថ្ងៃបន្ទាប់ពីការធ្វើតេស្ត ប៉ុន្តែ
    - ប្រសិនបើពួកគេកើតមានមានរោគសញ្ញា ពួកគេត្រូវអនុវត្តតាមការណែនាំខាងលើ

## 2. កំណត់អត្តសញ្ញាណនៃបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ នៅពេលមានកុមារមានឆ្លងមេរោគ។



នៅពេលដែលកុមារបានធ្វើតេស្តវិជ្ជមានសម្រាប់ជំងឺ COVID-19 ហើយឪពុកម្តាយត្រូវបានគេជូនដំណឹងរួចរាល់ហើយ ជំហានបន្ទាប់របស់សាលារៀនគឺត្រូវជូនដំណឹងដល់នាយកដ្ឋានសុខភាពសាធារណៈ។ សុខភាពសាធារណៈតាមដានកុមារគ្រប់រូបដែលបានលទ្ធផលធ្វើតេស្តវិជ្ជមានដោយពិនិត្យមើលថា តើអ្នកណាអាចជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនឹងកុមារដែលមានឆ្លងជំងឺនោះ។ គោលការណ៍របស់ខោនធី Los Angeles បានកំណត់ថាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមនុស្សម្នាក់ដែលឋិតនៅបរិវេណតិចជាង 6 ហ្វីតពីកុមារដែលមានឆ្លងមេរោគក្នុងរយៈពេលលើសពី 15 នាទីក្នុងអំឡុងពេល 24 ម៉ោង ឬអ្នកដែលបានប៉ះពាល់ដោយផ្ទាល់ទៅនឹងសារធាតុរាវនៃរាងកាយ និង/ឬសារធាតុបញ្ចេញផ្សេងៗរបស់កុមារ (ឧទាហរណ៍ ពេលក្អកឬកណ្តាស់ ប្រើប្រាស់ប្រដាប់ប្រដារួមគ្នា ឬជាប់ទឹកមាត់គ្នា)។

សុខភាពសាធារណៈសហការជាមួយសាលារៀនដើម្បីរៀបចំបង្កើតតារាងបញ្ជីកុមារ និងបុគ្គលិកដែលត្រូវបានគេចាត់ទុកថាជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនោះ។ ពួកយើងប្រមូលព័ត៌មានគ្រប់គ្រាន់ ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលចាំបាច់ត្រូវបញ្ជូនទៅផ្ទះដើម្បីដាក់ឱ្យធ្វើចត្តាឡីស័ក។ ពួកយើងកំពុងសហការយ៉ាងជិតស្និទ្ធជាមួយសាលារៀនដើម្បីបញ្ជាក់ថាបានកំណត់អត្តសញ្ញាណមនុស្សទាំងអស់ដែលចាំបាច់ត្រូវធ្វើចត្តាឡីស័ក និងថាអ្នកដែលមិនចាំបាច់ធ្វើចត្តាឡីស័កមិនខកខានថ្ងៃសិក្សាបន្ថែមនោះទេ។

### នេះគឺជាអ្វីដែលឪពុកម្តាយត្រូវដឹង អំពីកុមារណាដែលត្រូវធ្វើធ្វើចត្តាឡីស័ក ហើយកុមារណាខ្លះដែលមិនចាំបាច់ធ្វើចត្តាឡីស័ក

- កូនរបស់អ្នកមិនចាំបាច់ធ្វើចត្តាឡីស័កទេ ប្រសិនបើពួកគេត្រូវបានចាក់ថ្នាំបង្ការពេញលេញ និងគ្មានចេញរោគសញ្ញា។ បុគ្គលដែលបានចាក់ថ្នាំបង្ការក៏នៅតែអាចឆ្លងមេរោគដែលបង្កឱ្យមានជំងឺ COVID-19 បានដែរ ប៉ុន្តែបញ្ហានេះមិនកើតឡើងញឹកញាប់ទេ ហើយវាទំនងជាមិននាំឱ្យធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដែរ។ បុគ្គលដែលមិនបានចាក់ថ្នាំបង្ការនៅតែប្រឈមនឹងហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគ និងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ បើប្រៀបធៀបទៅនឹងបុគ្គលដែលបានចាក់ថ្នាំបង្ការគ្រប់ដូសនោះ។
    - ត្រូវប្រាកដថាសាលារៀនរបស់កូនអ្នកដឹងថា តើពួកគេបានចាក់ថ្នាំបង្ការពេញលេញដែរឬទេ។ សហការជាមួយសាលារៀនរបស់អ្នកដើម្បីផ្តល់ភស្តុតាងថាពួកគេបានចាក់ថ្នាំបង្ការរបស់ពួកគេរួចរាល់ហើយ។ នេះអនុញ្ញាតឱ្យសាលារៀនដឹងថាកូនរបស់អ្នកអាចនៅក្នុងសាលារៀន បន្ទាប់ពីមានការប៉ះពាល់ទៅនឹងមេរោគ។
    - ប្រសិនបើកូនរបស់អ្នកមានអាយុចាប់ពី 12 ឆ្នាំឡើងទៅ ប៉ុន្តែមិនទាន់ទទួលបានការចាក់ថ្នាំបង្ការនៅឡើយទេ អ្នកអាចជៀសវាងការធ្វើចត្តាឡីស័កនៅថ្ងៃក្រោយ ដោយគ្រាន់តែនាំពួកគេទៅចាក់ថ្នាំបង្ការឥឡូវនេះ។ មានទីតាំងចាក់ថ្នាំបង្ការរាប់រយកន្លែងមាននៅទូទាំងខោនធី រួមទាំងកន្លែងជាច្រើនដែលជាដៃគូជាមួយតំបន់សាលារៀន (school district) របស់អ្នក។ គ្រូពេទ្យជំនាញកុមាររបស់កូនអ្នកក៏អាច

ជួយរៀបចំថ្នាំបង្ការសម្រាប់កូនរបស់អ្នក និងឆ្លើយនឹងសំណួរឬកង្វល់ដែលអ្នកមានអំពីដំណើរការរបស់ថ្នាំបង្ការនានាផងដែរ។ សម្រាប់ព័ត៌មានបន្ថែមអំពីការចាក់ថ្នាំបង្ការនៃជំងឺ COVID-19 សម្រាប់កូនរបស់អ្នកសូមមើល ការពិតនៃថ្នាំបង្ការសម្រាប់ឪពុកម្តាយ។

- កូនរបស់អ្នកមិនចាំបាច់តម្រូវឱ្យធ្វើចត្តាឡីស័កទេ ប្រសិនបើពួកគេមិនមែនជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដែលបានឆ្លងមេរោគ។ ការស្ថិតនៅក្នុងថ្នាក់ឬកម្រិតថ្នាក់តែមួយ ឬនៅលើឡានក្រុងដឹកសិស្សតែមួយ មិនកំណត់ថាកូនរបស់អ្នកជាបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធដោយស្វ័យប្រវត្តិទេ។ សូមចងចាំនិយមន័យនេះៈ នៅក្នុងបរិវេណតិចជាង 6 ហ្វីតអស់រយៈពេលលើសពី 15 នាទីក្នុងអំឡុងពេលនៃថ្ងៃណាមួយ ឬបានប៉ះពាល់ដោយផ្ទាល់ទៅនឹងវត្ថុរាវនៃរាងកាយ និង/ឬសារធាតុបញ្ចេញផ្សេងៗ របស់មនុស្សដែលឆ្លងមេរោគ។
    - ប្រសិនបើពួកគេអង្គុយក្បែរកុមារដែលឆ្លងមេរោគនៅក្នុងថ្នាក់មួយឬច្រើនជាមួយគ្នា ពួកគេប្រហែលជាស្របតាមនិយមន័យនៃបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធ។ ចំណុចនេះក៏ចាត់ទុកថាដូចគ្នាដែរ ប្រសិនបើកូនរបស់អ្នកមានភាពស្និទ្ធស្នាលជាមួយកុមារដែលឆ្លងមេរោគនេះ នៅក្នុងទីតាំងសាលារៀនផ្សេងទៀត ដូចជាពេលអាហារថ្ងៃត្រង់ ឬពេលសម្រាកនៅខាងក្រៅអគារ។
- កូនរបស់អ្នកនឹងត្រូវដាក់ឱ្យធ្វើចត្តាឡីស័ក ប្រសិនបើពួកគេមិនបានចាក់ថ្នាំបង្ការ ឬមានរោគសញ្ញានៃជំងឺ ហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកឆ្លងមេរោគ។ នេះមានន័យថាពួកគេស្ថិតនៅក្នុងបរិវេណតិចជាង 6 ហ្វីតពីអ្នកឆ្លងមេរោគក្នុងរយៈពេលលើសពី 15 នាទីក្នុងអំឡុងពេល 24 ម៉ោង។
- គិតត្រឹមថ្ងៃទី 5 ខែតុលា ខោនធី Los Angeles បានអនុវត្តស្របនឹងសេចក្តីណែនាំនៃការធ្វើចត្តាឡីស័កដែលបានកែសម្រួល (modified quarantine) របស់រដ្ឋកាលីហ្វ័រញ៉ា។ ការធ្វើចត្តាឡីស័កដែលបានកែសម្រួលនេះធ្វើឱ្យកុមារដែលបានប៉ះពាល់នឹងជំងឺ COVID-19 នៅក្នុងថ្នាក់ ឬទីតាំងសាលារៀនផ្សេងមួយទៀត អាចបន្តទៅសាលារៀនបាន ដរាបណាស្របតាមល័ក្ខខ័ណ្ឌមួយចំនួនដែលបានកំណត់។ ការទទួលយកនូវគោលការណ៍ថ្មីនេះ គឺផ្អែកលើការពិនិត្យឡើងវិញនូវភ័ស្តុតាងដែលបានប្រមូលពីខែដំបូងនៃការបើកសាលារៀន ដោយសុខភាពសាធារណៈ ហើយដែលបានរកឃើញថា មានកុមារតិចតួចណាស់ដែលបានធ្វើចត្តាឡីស័កហើយមានជំងឺ COVID-19 នោះ។ ដោយសារហេតុផលនេះ ការធ្វើចត្តាឡីស័កដែលបានកែសម្រួលគឺជាជម្រើសមួយនាពេលឥឡូវនេះ ដែលសាលារៀនអាចសម្រេចចិត្តអនុវត្តសម្រាប់សិស្សមួយចំនួនបាន។ សូមមើល បច្ចុប្បន្នភាពដល់ឪពុកម្តាយអំពីការធ្វើចត្តាឡីស័កដែលបានកែសម្រួលសម្រាប់សាលារៀនកម្រិត TK-12 របស់សុខភាពសាធារណៈនៃខោនធី LA (LAC DPH)។
- សិស្សនានាដែលបានប៉ះពាល់នឹងមេរោគ អាចបញ្ចប់ការធ្វើចត្តាឡីស័ករបស់ពួកគេមុនពេលកំណត់ ហើយត្រឡប់ទៅសាលារៀនវិញបន្ទាប់ពី 7 ថ្ងៃជាជាងការរង់ចាំរហូតដល់បន្ទាប់ពី 10 ថ្ងៃ ប្រសិនបើសិស្សនោះធ្វើតេស្តរកមេរោគ COVID-19 នៅថ្ងៃទី 5 ឬថ្ងៃបន្ទាប់ពីនេះ ដោយទទួលបានលទ្ធផលអវិជ្ជមាន ហើយសិស្សមិនបានកើតមានរោគសញ្ញាណាមួយនៃជំងឺ COVID-19។ ប្រសិនបើកូនរបស់អ្នកមិនទទួលលទ្ធផលបានធ្វើតេស្តអវិជ្ជមាននៅថ្ងៃទី 5 ឬថ្ងៃបន្ទាប់ពីនេះទេ ពួកគេនឹងត្រូវធ្វើចត្តាឡីស័ករយៈពេល 10 ថ្ងៃពេញ។
- មនុស្សទាំងអស់ដែលប៉ះពាល់នឹងបុគ្គលដែលឆ្លងមេរោគ គួរតែតាមដានរោគសញ្ញាណាមួយនៃជំងឺសម្រាប់ខ្លួនឯងផ្ទាល់រយៈពេល 14 ថ្ងៃ ចាប់ពីការប៉ះពាល់ចុងក្រោយរបស់ពួកគេទៅនឹងមនុស្សដែលឆ្លងមេរោគ ពីព្រោះមេរោគនេះអាចស្ថិតនៅក្នុងខ្លួនដោយមិនបញ្ចេញរោគសញ្ញាបានលើសពី 14 ថ្ងៃ។

នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles ប្រមូលព័ត៌មានអំពីការឆ្លងមេរោគ និងការប៉ះពាល់ជារៀងរាល់ថ្ងៃ។ ព័ត៌មាននេះនឹងអនុញ្ញាតឱ្យពួកយើងសម្រេចចិត្តថា តើត្រូវរក្សាទុកឬផ្លាស់ប្តូរគោលការណ៍នៃការធ្វើចត្តាឡីស័កនាពេលបច្ចុប្បន្ន ដោយផ្អែកលើព័ត៌មានអំពីចំនួនការឆ្លងមេរោគដែលកំពុងកើតឡើងនៅតាមសាលារៀន។

## 3. អ្វីដែលសាលារៀនអាចធ្វើបាន និងវិធីដែលអ្នកអាចជួយកាត់បន្ថយការប៉ះពាល់នឹងមេរោគនិងការធ្វើចត្តាឡីស័កសម្រាប់ K-12។

សុខភាពសាធារណៈបានធ្វើបច្ចុប្បន្នកម្មលើគោលការណ៍ពីឆ្នាំមុន ដើម្បីអនុញ្ញាតសិស្សឱ្យបានចូលរៀនដោយផ្ទាល់ពេញលេញនៅក្នុងសាលារៀនវិញ។ ឆ្នាំនេះ ជំហាននានាដែលសាលារៀនទាំងអស់ត្រូវតែអនុវត្តគឺៈ



- ពួកគេត្រូវតែធានាថាមនុស្សគ្រប់រូបនៅក្នុងទីតាំងសាលារៀន TK-12 មានការពាក់ម៉ាស់គ្រប់ពេលនៅពេលដែលនៅខាងក្នុងអគារ លើកលែងតែពេលញ៉ាំអាហារឬភេសជ្ជៈប៉ុណ្ណោះ។
- ពួកគេត្រូវរាយការណ៍ទៅសុខភាពសាធារណៈក្នុងចន្លោះពេល 24 ម៉ោងរាល់ពេលដែលបានកំណត់សញ្ញាណករណីវិជ្ជមានមួយនៅក្នុងសាលារៀន។
- ពួកគេត្រូវរាយការណ៍ទៅកាន់សុខភាពសាធារណៈជាបន្ទាន់ រាល់ពេលដែលបានកំណត់សញ្ញាណករណីចំនួន 3 ឬច្រើនជាងនេះនៅក្នុងបរិវេណសាលារៀនតែមួយក្នុងអំឡុងពេល 14 ថ្ងៃ។
- ពួកគេត្រូវតែមានផែនការនៃការបង្ការជំងឺ COVID-19 ដែលរួមទាំងផែនការគ្រប់គ្រងការប៉ះពាល់។ ផែនការនេះត្រូវតែមានសម្រាប់សហគមន៍សាលារៀនទាំងមូល។

លើសពីតម្រូវការទាំងនេះ មានជំហានបន្ថែមទៀតដែលសាលារៀនអាចអនុវត្តបានដើម្បីកាត់បន្ថយការរីករាលដាលនៃជំងឺ COVID-19។ ជំហានទាំងនេះអាចជួយកាត់បន្ថយចំនួនកុមារដែលត្រូវការធ្វើចត្តាឡីស័កនៅពេលបានកំណត់សញ្ញាណករណីឆ្លងមេរោគមួយនៅសាលារៀន។ ជំហានទាំងនេះរួមមាន៖

- រៀបចំឱ្យសិស្សអង្គុយនៅកៅអីដដែលរាល់ថ្ងៃ និងរក្សាតារាងកន្លែងអង្គុយនោះ។ ជំហានដ៏សាមញ្ញនេះជួយឱ្យសាលារៀនកំណត់បានត្រឹមត្រូវថា តើកុមារណាខ្លះស្ថិតក្នុងបរិវេណ 6 ហ្វីតនៃកុមារដែលបានឆ្លងមេរោគ និងកំណត់ចំនួនសិស្សដែលត្រូវបានបញ្ជាក់ថាពួកគេត្រូវទៅផ្ទះ និងធ្វើចត្តាឡីស័ក។
- នៅក្នុងសាលារៀនបឋមសិក្សា វាអាចជួយដោយរៀបចំឱ្យសិស្សបរិភោគអាហារជាក្រុមកុមារតែមួយជាមួយសិស្សដែលអង្គុយនៅក្នុងថ្នាក់ជារៀងរាល់ថ្ងៃ។ សូមបញ្ជាក់ម្តងទៀត ចំណុចនេះកាត់បន្ថយចំនួនកុមារដែលបានប៉ះពាល់នឹងមេរោគ នៅពេលមានករណីឆ្លងកើតឡើង។
- ប្រើទីតាំងខាងក្រៅឱ្យបានញឹកញាប់ តាមដែលអាចធ្វើទៅបាន។ ខ្យល់បក់ធម្មជាតិធ្វើឱ្យបរិយាកាសនៅខាងក្រៅក្លាយជាកន្លែងដែលមានសុវត្ថិភាពបំផុត។ សាលារៀនអាចរៀបចំថ្នាក់រៀននៅខាងក្រៅអគារ អនុញ្ញាតឱ្យសិស្សបរិភោគអាហារថ្ងៃត្រង់នៅខាងក្រៅ និងប្រើទីធ្លាខាងក្រៅសម្រាប់ថ្នាក់ហាត់ប្រាណឬកីឡា និងការសម្រាកជាដើម។
- ការរារាំងការប្រមូលផ្តុំមនុស្សច្រើនកុះករ។ សាលារៀនអាចបង្កើនគម្លាតសង្គមនៅទីតាំងណាតាមដែលអាចធ្វើទៅបាន។ បុគ្គលិកសាលារៀនអាចកំណត់ពេលវេលានិងកន្លែងដែលសិស្សប្រមូលផ្តុំគ្នា និងបង្កើតគោលការណ៍គ្រប់គ្រងក្រុមមនុស្ស ដើម្បីលើកកម្ពស់ការរក្សាចម្ងាយ 6 ហ្វីតរវាងកុមារនិងកុមារ នៅពេលដែលពួកគេនៅក្រៅថ្នាក់រៀន។



- ដាក់ឱ្យកុមារអង្គុយ ដោយឱ្យពួកគេបែរមុខទៅទីតាំងដូចគ្នា និងនៅឆ្ងាយពីគ្នាតាមដែលអាចធ្វើទៅបាន ពេលនៅក្នុងថ្នាក់រៀនរបស់ពួកគេ។ សាលារៀនគួរតែចៀសវាងកន្លែងអង្គុយដែលមានកៅអីទល់មុខគ្នា និងនៅក្បែរគ្នា។
- មានប្រព័ន្ធខ្យល់ដែលដំណើរការបានល្អ ហើយដែលមានខ្យល់បក់ចេញពីថ្នាក់រៀន។
- ការផ្តល់ទីតាំងលាងដៃ ឬទឹកអនាម័យលាងដៃជាច្រើនកន្លែងនៅទូទាំងសាលារៀន។ នេះធ្វើឱ្យសិស្សនិងបុគ្គលិកមានភាពងាយស្រួលក្នុងការលាងសម្អាតដៃ ឬប្រើទឹកអនាម័យលាងសម្អាតដៃរបស់ពួកគេឱ្យបានញឹកញាប់។

## ត្រូវការជំនួយពីអ្នក។

ទីមួយ ប្រសិនបើសាលារៀនរបស់កូនអ្នកមិនមានឱកាសអនុវត្តជំហានបង្ការមួយចំនួនដែលបានរៀបរាប់ខាងលើនោះទេ សូមស្នើទៅគ្រូនិងអ្នកគ្រប់គ្រងសាលារៀន។

ទីពីរ អប់រំកូនរបស់អ្នកអំពីតួនាទីរបស់ពួកគេក្នុងការរក្សាសុវត្ថិភាពសាលារៀន។

- ត្រូវប្រាកដថាកូនរបស់អ្នកយល់ពីសារៈសំខាន់នៃការពាក់ម៉ាស់ពេលនៅខាងក្នុងអគារ និងដឹងអំពីរបៀបពាក់ម៉ាស់ឱ្យបានត្រឹមត្រូវ ដូច្នេះម៉ាស់បិទជិតល្អ ហើយគ្របមុខរបស់ពួកគេពីច្រមុះដល់ចង្កា។

- អប់រំកូនរបស់អ្នកអំពីសារៈសំខាន់នៃការអនុវត្តតាមច្បាប់សាលារៀនពាក់ព័ន្ធទីតាំងអង្គុយ ការរក្សាគម្លាត និងការជៀសវាងការប្រមូលផ្តុំមនុស្សច្រើនកុះករ។ ត្រូវប្រាកដថាកូនរបស់អ្នកយល់ពីទំនាក់ទំនងរវាងអាកប្បកិរិយាទាំងនេះ និងវិធីដែលពួកគេចូលរួមជួយដើម្បីរារាំងការរីករាលដាលនៃមេរោគ។

ហើយប្រសិនបើអ្នកចង់អនុវត្តលើសពីនេះទៀត អ្នកអាចចុះឈ្មោះក្នុង **កម្មវិធីឯកអគ្គរដ្ឋទូតឪពុកម្តាយរបស់ DPH!** ពួកយើងផ្តល់ការបណ្តុះបណ្តាល និងវិញ្ញាបនប័ត្រដល់ឪពុកម្តាយដែលចង់ទទួលបានការអប់រំអំពីជំងឺ COVID-19 របៀបដែលមេរោគរីករាលដាល ផលប៉ះពាល់របស់មេរោគទៅលើសុខភាពកុមារ និងវិធីដែលយើងទាំងអស់គ្នាអាចសហការគ្នាដើម្បីចៀសវាងការរីករាលដាល។ អ្នកនឹងចូលរួមជាមួយក្រុមអ្នកដឹកនាំឪពុកម្តាយដ៏អស្ចារ្យ ដែលជួយចែករំលែកការពិតអំពីជំងឺ COVID-19 ជាមួយសហគមន៍សាលារៀនទាំងមូល។

**ដើម្បីស្វែងយល់បន្ថែម សូមផ្ញើរអ៊ីមែលទៅកាន់៖** TK12Ambassador@ph.lacounty.gov

## ប្រភពឯកសារធនធានសម្រាប់ជំងឺ COVID-19

**ខោនធី Los Angeles** ph.lacounty.gov/coronavirus
**មជ្ឈមណ្ឌលគ្រប់គ្រងនិងទប់ស្កាត់ជំងឺឆ្លង (CDC)**៖ www.cdc.gov/coronavirus

### ព័ត៌មានសម្រាប់អ្នកដែលមានជំងឺ COVID-19 និងបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធរបស់ពួកគេ៖

- សេចក្តីណែនាំឲ្យដាក់នៅដាច់ដោយឡែកសម្រាប់អ្នកជំងឺ COVID-19៖ ph.lacounty.gov/covidisolation
- សេចក្តីណែនាំអំពីការធ្វើចត្តាឡីស័ក និងសេចក្តីណែនាំផ្សេងទៀតសម្រាប់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធ៖ ph.lacounty.gov/covidquarantine
- ថែទាំអ្នកមានជំងឺនៅផ្ទះ (Caring for someone sick at Home)៖ គេហទំព័ររបស់ CDC
- សម្រាប់ជំនួយក្នុងការស្វែងរកការថែទាំសុខភាព ឬការទទួលបានការផ្គត់ផ្គង់សម្ភារចាំបាច់៖ សូមទូរស័ព្ទមកលេខ 2-1-1 ឬចូលទៅកាន់គេហទំព័រ 211LA.org

### ព័ត៌មានស្តីពីការចាក់ថ្នាំបង្ការ៖

- CDC៖ www.cdc.gov/coronavirus/2019-ncov/vaccines
- ខោនធី Los Angeles៖ VaccinateLACounty.com ឬក៏ VacunateLosAngeles.com (ភាសាអេស្ប៉ាញ)
- ដើម្បីស្វែងរកថ្នាំបង្ការដោយឥតគិតថ្លៃនៅជិតអ្នក សូមចូលទៅកាន់គេហទំព័រ **VaccinateLACounty.com** ហើយចុចលើ "**វិធីទទួលការចាក់ថ្នាំបង្ការ**" ("How To Get Vaccinated") ឬក៏ទូរស័ព្ទទៅ**មជ្ឈមណ្ឌលព័ត៌មានថ្នាំបង្ការរបស់ DPH** តាមរយៈលេខ **833-540-0473**។ មិនចាំបាច់តម្រូវឱ្យធ្វើការណាត់ជួបទេ នៅតាមទីតាំងជាច្រើន។ អ្នកមិនតម្រូវចាំបាច់មានការធានារ៉ាប់រង ហើយអ្នកនឹងមិនត្រូវបានសួរអំពីស្ថានភាពអន្តោប្រវេសន៍ឡើយ។

### ព័ត៌មានស្តីពីការបង្ការសម្រាប់ឪពុកម្តាយនិងអាណាព្យាបាល៖

- សូមចូលមើលឯកសារធនធាននៃជំងឺ COVID-19 សម្រាប់ឪពុកម្តាយ និងអាណាព្យាបាលតាមរយៈ គេហទំព័រ។ ឯកសារធនធានដែលមាននៅលើទំព័រនេះ រួមមាន៖ ការបង្ការជំងឺ COVID-19 នៅក្នុងសាលារៀនកម្រិត TK-12 គេហទំព័រស្តីពីម៉ាស់៖ ph.lacounty.gov/masks និងគេហទំព័រ ការរក្សាសុវត្ថិភាព និងបង្ការការរីករាលដាលសម្រាប់ឪពុកម្តាយដែលមានកូនអាយុក្រោម 12 ឆ្នាំ។